**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៨៣ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការកាត់ឆ្វៃដីទំហំ ៣ ១៦៤ ហិកតា ៨០ អា ១០ សង់ទីអា ចេញពីដីរបៀងជីវៈចម្រុះ ប្រព័ន្ធតំបន់ការពារធម្មជាតិ និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនគ្រួសារក្រីក្រទួទៅដែលខ្វះដី ស្ថិតក្នុងភូមិសាស្ត្រចំណុចអូរសែង ឃុំភ្លុក ឃុំស្រែគរ និងឃុំសាមឃួយ ស្រុកសេសាន ខេត្តស្ទឹងត្រែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្ដីពីសម្បទានដីសង្គមកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១.-**

កាត់ផ្ទៃដីទំហំ ៣ ១៦៤ ហិកតា ៨០ អា ១០ សង់ទីអា ចេញពីដីរបៀងជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនគ្រួសារក្រីក្រទូទៅដែលខ្វះដី ក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី៣ (LASED III) ស្ថិតក្នុងភូមិសាស្ត្រចំណុចអូរសែវ ឃុំភ្លុក ឃុំស្រែគរ និងឃុំសាមឃួយ ស្រុកសេសាន ខេត្តស្ទឹងត្រែង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ខាងលើ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តស្ទឹងត្រែង ដើម្បីធ្វើការគ្រប់គ្រងនិងចាត់ចែងស្របតាមនីតិវិធីជាធរមាន។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីនិងតារាងនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០២១




តារាងនិយាមការចំណុចព្រំដី

WGS_1984_UTM_Zone_48N

| ID | X(m) | Y(m) |
|---|---|---|
| 1 | 636001.000 | 1514715.000 |
| 2 | 642003.973 | 1514711.536 |
| 3 | 642001.012 | 1509883.671 |
| 4 | 640597.250 | 1509381.000 |
| 5 | 636001.000 | 1509381.000 |

ផែនទីកាត់ឆ្វៃដីទំហំ ៣ ១៦៤ ហិកតា ៨០ អា ១០ សង់ទីអា ចេញពីដីរបៀងជីវៈចម្រុះ
ប្រព័ន្ធតំបន់ការពារធម្មជាតិ និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ
សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនគ្រួសារក្រីក្រគោលដៅដែលខ្វះដី ស្ថិតក្នុងភូមិសាស្ត្រចណ្ដុចអូរសេង
ឃុំត្បូង ឃុំស្រែគរ និងឃុំសាមឃួយ ស្រុកសេសាន ខេត្តស្ទឹងត្រែង




| WGS_1984_UTM_Zone_48N | | |
|---|---|---|
| ID | X(m) | Y(m) |
| 1 | 636001.000 | 1514715.000 |
| 2 | 642003.973 | 1514711.536 |
| 3 | 642001.012 | 1509883.671 |
| 4 | 640597.250 | 1509381.000 |
| 5 | 636001.000 | 1509381.000 |